00890192

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26 / 02 / 2013
ម៉ោង (Time/Heure) : 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

E264/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**

**សាធារណៈ / Public**

ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣

**ជូនចំពោះ៖** ភាគីនៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក /លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង មន្ត្រីសម្របសម្រួលនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ

**កម្មវត្ថុ៖** ការកំណត់កាលបរិច្ឆេទរបស់អ្នកជំនាញ Philip Short និង Elizabeth Becker និងការពន្យារពេលស្តាប់សក្ខីកម្មសាក្សីពាក់ព័ន្ធនឹងអង្គហេតុ រហូតដល់មានសេចក្តីសម្រេចថ្មីអំពីការបំបែកកិច្ចដំណើរការនីតិវិធីសវនាការ

១. បន្ទាប់ពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់ភាគីនានា ក្រោយពេលអង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចរបស់ខ្លួនកាលពីពេលថ្មីៗនេះស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E163/5/1/13) រួមទាំងសំណួរមួយចំនួនដែលអង្គជំនុំជម្រះសាលាដំបូងបានចោទសួរទៅភាគីនោះ (ឯកសារ E163/5/1/ 13/1, E264) នាពេលនេះ អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីណែនាំដូចខាងក្រោមសម្រាប់សប្តាហ៍បន្តបន្ទាប់ខាងមុខ។

២. អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មរបស់អ្នកជំនាញ Philip SHORT ចាប់ពីថ្ងៃចន្ទ ទី ០៤ ខែ មីនា ឆ្នាំ ២០១៣ និង Elizabeth BECKER ចាប់ពីថ្ងៃចន្ទទី ១១ ខែ មីនា ឆ្នាំ ២០១៣ ដូចដែលបានគ្រោងទុកកាលពីពេលមុន។ បន្ថែមពីលើនេះ អង្គជំនុំជម្រះសូមរំឭកភាគីអំពីសេចក្តីណែនាំមុនរបស់អង្គជំនុំជម្រះដែលថាអ្នកជំនាញទាំងពីរនេះនឹងត្រូវបានសួរសំណួរ “ស្តីពីបញ្ហាទាំងអស់ដែលពួកគាត់មានសមត្ថភាពផ្តល់សក្ខីកម្មនៅក្នុងវិសាលភាពនៃដីកា

ដំណោះស្រាយក្នុងសំណុំរឿងលេខ០០២” (ឯកសារ E174/24)។ ថ្វីបើអង្គជំនុំជម្រះបាន លើកទឹកចិត្តឲ្យភាគីផ្តោតសំណួរអំពីវិសាលភាពនៃការជំនុំជម្រះ ដូចដែលត្រូវបានបំបែកកាល ពីពេលមុនក៏ដោយ (ឯកសារ E236/4) ក៏ការសួរសំណួរនៅតែបើកចំហលើរាល់ប្រធានបទ ទាំងអស់នៅក្នុងសំណុំរឿងលេខ០០២។ ហេតុដូច្នេះ អង្គជំនុំជម្រះពិចារណាឃើញថាការ ស្តាប់សក្ខីកម្មរបស់អ្នកជំនាញទាំង ០២ រូបនេះ មុនពេលមានសេចក្តីសម្រេចថ្មីមួយស្តីពីការ បំបែកកិច្ចដំណើរការនីតិវិធីសវនាការ ពុំមានប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីឡើយ ដោយហេតុថាវិសាលភាពនៃការសួរសំណួរមិនមានការប្រែប្រួល បើទោះបីជាមានសេចក្តី សម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក៏ដោយ។

៣. យ៉ាងណាមិញ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាការស្តាប់សក្ខីកម្មរបស់សាក្សីដែល មានរហស្សនាម TCW-100, TCW-110, TCW-724 ឬ TCW-794 មុនពេលមានសេចក្តី សម្រេចថ្មីមួយស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនឹងនាំឲ្យមានមន្ទិលអំពីវិសាលភាពនៃការ សួរសំណួរ។ ហេតុដូច្នេះ អង្គជំនុំជម្រះនឹងពុំទាន់ស្តាប់សក្ខីកម្មរបស់សាក្សីទាំងនេះឡើយ នៅ ពេលពុំទាន់មានសេចក្តីសម្រេចថ្មីមួយស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីសវនាការ។

៤. អង្គជំនុំជម្រះពិចារណាឃើញថា ភស្តុតាងដែលនឹងផ្តល់ដោយអ្នកជំនាញ វេជ្ជសាស្ត្រ គឺមាន ភាពចាំបាច់ចំពោះការចេញសេចក្តីសម្រេចថ្មីរបស់ខ្លួនស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី សវនាការ។ ហេតុដូចនេះ អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចដែលមានសម្អាងហេតុពេញ លេញពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធីសវនាការក្រោយពីបានស្តាប់សក្ខីកម្មរបស់ អ្នកជំនាញវេជ្ជសាស្ត្រខាងលើរួចរាល់។ នាពេលបច្ចុប្បន្ន អ្នកជំនាញវេជ្ជសាស្ត្រគ្រោងនឹងធ្វើ ដំណើរមកដល់ភ្នំពេញនាពាក់កណ្តាលខែ មីនា និងផ្តល់សក្ខីកម្មក្នុងអំឡុងថ្ងៃចន្ទទី ២៥ ខែ មីនា ឆ្នាំ ២០១៣។

៥. អង្គជំនុំជម្រះសូមបញ្ជាក់ផងដែរថា សំណើសុំរបស់ជនជាប់ចោទ ខៀវ សំផន គឺជាសំណើ មិនចាំបាច់ ដោយហេតុថា អង្គជំនុំជម្រះបានសម្រេចពន្យាពេលស្តាប់សក្ខីកម្មសាក្សីអត្តចរិត ពាក់ព័ន្ធនឹងជនជាប់ចោទរូបនេះ។ នេះជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះទៅនឹង ឯកសារ E263/5/1 ។